مدرسة اهل البيت

صلوات الله عليهم

# សាលា

# អាស្ហ់លុល-បៃត៍

## សៀវភៅសិក្សា គួរអាន (اَلْقُرْآنُ) ថ្នាក់ទី ៤

(អាយុ ៨-៩ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ អារម្ភបទនិងសព្ទបច្ចេកទេស ........ ៥
មេរៀនទី ២ ស៊ូរ៉ោះត៍ អាល់-ហ្វីល - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៩
មេរៀនទី ៣ ស៊ូរ៉ោះត៍ អាល់-ហ្វីល - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ១០
មេរៀនទី ៤ ស៊ូរ៉ោះត៍ អាល់-ក្វដ្រ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ១៤
មេរៀនទី ៥ ស៊ូរ៉ោះត៍ អាល់-ក្វដ្រ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ១៦
មេរៀនទី ៦ ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة) - ហ៊្វរុហ្វ អ៊ីស្ហហារ (الإظْهَار) ........ ១៩
មេរៀនទី ៧ ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة) - ហ៊្វរុហ្វ អ៊ីក្វឡាប់ (ឬ ក្វល់ប៍ القلب/ الإقلاب) ........ ២១
មេរៀនទី ៨ ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة) - ហ៊្វរុហ្វ អ៊ីដ្ហកុំ ........ ២៤
មេរៀនទី ៩ ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة) - ហ៊្វរុហ្វ អ៊ិះខ្ហ៊ហ្វាអ៍ (الإِخْفَاء) ........ ២៧
មេរៀនទី ១០ ស៊ូរ៉ោះត៍ អាល់-ឡាហ្ស៊ាប់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៣០
មេរៀនទី ១១ ស៊ូរ៉ោះត៍ អាល់-ឡាហ្ស៊ាប់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៣១
មេរៀនទី ១២ ស៊ូរ៉ោះត៍ អាន់-ណាស៊្រ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៣៣
មេរៀនទី ១៣ ស៊ូរ៉ោះត៍ អាន់-ណាស៊្រ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៣៥
មេរៀនទី ១៤ ស៊ូរ៉ោះត៍ អាល់-កៅស្ហារ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៣៨
មេរៀនទី ១៥ ស៊ូរ៉ោះត៍ អាល់-អាុស្រ៍ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ........ ៤១

# اَلْقُرْآنْ



ឈ្មោះខ្ញុំ ៖...........................................................

ឈ្មោះខ្ញុំជាភាសាអារ៉ាប់ ៖

.....................................................................

## មេរៀនទី ១

# អារម្ភបទនិងសព្ទបច្ចេកទេស

### ព្រះមហាគម្ពីរគួរអានគឺអ្វី ?

ព្រះមហាគម្ពីរគួរអានគឺសៀវភៅ ឬ តម្រា ដែលមានចារនូវព្រះរាជបន្ទូល (គឺសម្ដី) របស់អល់ឡោះហ៍ﷻ ។

### អ្នកណាតែងព្រះមហាគម្ពីរគួរអានឡើង ?

មិនមានអ្នកណាតែងព្រះគម្ពីរគួរអានឡើងទេ ។ អល់ឡោះហ៍ﷻបានបញ្ជូនពាក្យពេជន៍មកឲ្យព្រះសាស្ដាﷺ (ណាប៊ី) តាមរយៈទេវតាឈ្មោះយ៉ីប៉រ៉អ៊ីលعليه السلام ។

បន្ទាប់មកព្រះសាស្ដាﷺបានសូត្រព្រះរាជឱង្ការ (អាយ៉ាត់) ប្រាប់មនុស្ស ។ មនុស្សភាគច្រើនចងចាំព្រះរាជឱង្ការរត់មាត់ តែព្រះសាស្ដាﷺបានចាត់តាំងមនុស្សពីរបីនាក់ដើម្បីសរសេរព្រះឱង្ការទុក ។

### ព្រះមហាគម្ពីរគួរអានត្រូវសរសេរជាភាសាអ្វី ?

ព្រះគម្ពីរគួរអានត្រូវសរសេរឡើងជាភាសាអារ៉ាប់ ។ ភាសាអារ៉ាប់សរសេរពីខាងស្ដាំមកខាងឆ្វេង ។

### អល់ឡោះហ៍ﷻមានព្រះរាជបន្ទូលថាអ្វីនៅក្នុងព្រះមហាគម្ពីរគួរអាន ?

អល់ឡោះហ៍ﷻរៀបរាប់ប្រាប់នូវរឿងពិតរបស់ព្រះសាស្ដានានាعليهم السلام ។

អល់ឡោះហ៍ﷻប្រាប់អំពីទង្វើដែលយើងត្រូវធ្វើ ។

អល់ឡោះហ៍ﷻរៀបរាប់ប្រាប់យើងឲ្យដឹងអំពីឋានសួគ៌និងឋាននរក ។

អល់ឡោះហ៍ﷻរៀបរាប់ប្រាប់យើងច្រើនរឿងណាស់ ។ យើងនឹងយល់រឿងមួយចំនួនពេលយើងធំបន្តិច ។ យើងនឹងយល់រឿងឯទៀតលុះត្រាយើងត្រឡប់ទៅឯ

ព្រះអង្គﷻវិញ ព្រះអង្គﷺនឹងពន្យល់ប្រាប់យើង ។

# ការគោរពព្រះមហាគម្ពីរគួរអាន

យើងត្រូវថែទាំព្រះមហាគម្ពីរគួរអានព្រោះវាជាសៀវភៅពិសេស ។ តើអ្នកត្រូវធ្វើម្ដេច ?

យើងត្រូវកាន់ ចាប់ ឬប៉ះព្រះមហាគម្ពីរគួរអានដោយសេចក្ដីគោរព (គ្រូត្រូវបង្ហាញសិស្ស) ។

យើងមិនត្រូវបើកព្រះមហាគម្ពីរគួរអានចោលជាដាច់ខាត បើពុំមានអ្នកណាសូត្រទេនោះ ។

យើងមិនត្រូវប៉ះតួអក្សរ (ហ៊្វរុហ្វ اَلْحُرُوف) ព្រះមហាគម្ពីរគួរអានទេ បើពុំទាន់បានយកទឹកវូឌុអ៍ជាមុនសិនទេនោះ ។ គេអាចសូត្រ (ឬអាន) ព្រះមហាគម្ពីរគួរអានបានដោយមិនប៉ះតួអក្សរ ឬដោយដាក់សន្លឹកផ្លាស្ទិចថ្លាទ្រាប់ពីលើសន្លឹកទំព័រព្រះមហាគម្ពីរគួរអាននោះបាន ។

ស៊ូណាត់ (អល់ឡោះហ៍ﷺសព្វព្រះហឫទ័យបើព្យាយាមធ្វើ) ពេលសូត្រព្រះមហាគម្ពីរគួរអាន គឺ៖

-គ្របក្បាល - ដោយមួកម្យ៉ាង(កន្ដឹប)សម្រាប់ប្រុស ដោយក្រណាត់ទទូរក្បាលសម្រាប់ស្រី ។

-បែរមុខទៅរកគិ្លបឡាត់ពេលគេសូត្រព្រះមហាគម្ពីរគួរអាន ។

យើងសូត្រថា អាអ៊ូស៊ូ ប៊ិលឡាហ៊ី មីណាស្ស៊ៃត្វ៉នីរ៉ជីម (أَعُوذُ بِاللَّهِ مِنَ الشَّيْطَانِ الرَّجِيمِ) និង ប៊ិសមិលឡាហ៊ី រ៉ោះហ៍ម៉ានីរ៉ហ៊ីម (بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ) មុនចាប់ផ្ដើមសូត្រព្រះមហាគម្ពីរគួរអាន ។

# សព្ទបច្ចេកទេស

-حَرْفٌ ហារហ្វ៍ (ពហុវចនៈ حُرُوف ហ៊្វរុហ្វ) - តួអក្សរនៃព្យញ្ជនៈអារ៉ាប់ ។

-نُقْطَة នុក្តោះត៍ (ពហុវចនៈ نُقَط នូក្កត់) - ចំណុចពីលើឬពីក្រោមហ៊្វរុហ្វ ។

-حَرَكَة ហារ៉កាស់ (ពហុវចនៈ حَرَكَات ហារ៉កាត់) - សញ្ញាវណ្ណយុត្តសម្រាប់ប្រើផ្សំជាមួយហ៊្វរុហ្វ មាន៖

-ហ្វាត់ហាស់ (اَلْفَتْحَةُ)

-កាស់រ៉ោះត៍ (اَلْكَسْرَةُ)

-ដ្ធំម៉ាស់ (اَلضَّمَّةُ)

-مَخْرَج ម៉ាក់រ៉ច់ (ពហុវចនៈ مَخَارِج ម៉ាខ៉ូរីច្ច) - របៀបថាឲ្យត្រូវតាមសម្លេងហ៊្វរុហ្វ ។

-آيَة អាយ៉ាស់ (ពហុវចនៈ آيَات អាយ៉ាត់) - ព្រះគាថារបស់គួរអាន ។

-سُورَة ស៊ូរ៉ោះត៍ (ពហុវចនៈ سُوَر ស៊ូវ៉ារ) - ចំពូកនីមួយនៃចំពូកទាំង ១១៤ របស់គួរអាន ។

-وَقْف វ៉ាក់ហ្វ៍ (ពហុវចនៈ وُقُوف វូគូហ្វ) - សញ្ញាឈប់ឬដាក់ ។

-جُزْء យូស្អ៊ុ (ពហុវចនៈ أَجْزَاء អាច់ស្សាអ៊ុ) - គេបែងចែកគួរអានជា ៣០ ប៉ែកស្មើ ។ គេហៅប៉ែកនីមួយៗថាយូស្អ៊ុ ។

-رُبْع រុបអ៊ុ - សញ្ញាបញ្ជាក់មួយភាគបួននៃយូស្អ៊ុ ។

-نِصْف នីស្វហ្វ៍ - សញ្ញាបញ្ជាក់មួយភាគពីរនៃយូស្អ៊ុ ។

-ثُلُث ស្ទុលុស្ទ - សញ្ញាបញ្ជាក់បីភាគបួននៃយូស្អ៊ុ ។

# ការអនុវត្តិ ១

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

أَعُوذُ بِاللَّهِ مِنَ الشَّيْطَانِ الرَّجِيمِ

*ខ្ញុំសូមជ្រកកោនក្រោមព្រះជម្រកអល់ឡោះហ្ជ៏ﷻឲ្យចាកផុតមារស្ហៃតនﷺត្រូវបណ្តាសា*

២) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ជ៏ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី*

៣) ចូរផាត់ពណ៌រូបក្នុងទំព័រទី ៣ គឺរូបត៌្មលិបសូត្រគួរអានខាងលើ ហើយសរសេរឈ្មោះអ្នក (លោក/អ្នកគ្រូសរសេរឈ្មោះសិស្សជាភាសាអារ៉ាប់) ។

៤) ចូរអ្នកយកសន្លឹកផ្លាស្ទិចថ្លាមួយបន្ទះមកអនុវត្តិការប្រើប្រាស់ ។

៥) ចូរកាត់ក្រដាសរឹងងមួយបន្ទះតូចទ្រវែង ស្រួចមុខហើយផាត់ពណ៌បន្ទះក្រដាសនោះ ។ ប្រើបន្ទះក្រដាសនេះសម្រាប់សូត្រគួរអានជំនួសចង្អុលដៃ ។

## មេរៀនទី ២

# ស៊ូរ៉ោះតុ៍ អាល់-ហ្វីល - ទន្ទេញចាំរត់មាត់ - តាហ្ស់សៀរ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

*ដោយនូវព្រះនាមអល់ឡោះហ្វ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

أَلَمْ تَرَ كَيْفَ فَعَلَ رَبُّكَ بِأَصْحَابِ الْفِيلِ ۝

*អ្នកមិនបានឃើញទេ ថាព្រះម្ចាស់អ្នកបានប្រព្រឹត្តដូចម្ដេចខ្លះលើបនម្ចាស់ដំរី ?*

أَلَمْ يَجْعَلْ كَيْدَهُمْ فِيْ تَضْلِيْلٍ ۝

*ព្រះអង្គមិនបានធ្វើឲ្យឧបាយកលពួកគេភាន់ខូចអស់ទេ ?*

وَأَرْسَلَ عَلَيْهِمْ طَيْرًا أَبَابِيْلَ ۝

*ព្រះអង្គបានបញ្ជូនហ្វូងសត្វស្លាបទៅតទល់ស៊ូនឹងពួកគេ*

تَرْمِيْهِمْ بِحِجَارَةٍ مِنْ سِجِّيلٍ ۝

*ដោយចោលដុំថ្មឥដ្ឋទៅលើពួកគេ ។*

فَجَعَلَهُمْ كَعَصْفٍ مَّأْكُوْلٍ ۝

*ព្រះអង្គធ្វើឲ្យពួកគេទៅជាដូចចំបើងទំពាលម្អិត ។*

អល់ឡោះហ្វ៍ﷻបានដាក់ស៊ូរ៉ោះតុ៍នេះមកនៅឯម៉ាក់កាស្ង៉ មាន ៥ អាយ៉ាស្ង៉ ។ "អាល់-ហ្វីល" មានន័យ ថា "ដំរី" ។ ឈ្មោះស៊ូរ៉ោះតុ៍នេះមកពីទ័ពដំរីចែងនៅក្នុង អាយ៉ាស្ង៉ ១ ។

## មេរៀនទី ៣

# ស៊ូរ៉ោះត៊ុ៍ អាល់-ហ្វីល - ទន្សេញចាំរត់មាត់ - តាហ្ស៊ៀវ

ឆ្នាំ ៥៧០ នៃគ្រិស្តសករាជ គឺឆ្នាំដែលព្រះសាស្តាﷺយើងប្រសូត អភិបាលនគរកាន់សាសនាគ្រិស្តឈ្មោះ អាប់រ៉ហ្វាស្ហ៊ុ បានលើកទ័ពមកកម្ទេចព្រះមហាគ្រឹះកាក់ុបាស្ហ៊ុ ។ មូលហេតុដែលអាប់រ៉ហ្វាស្ហ៊ុកម្ទេចកាក់ុបាស្ហ៊ុនោះ ព្រោះតែចង់ឲ្យមនុស្សចោលម៉ាក់កាស្ហ៊ុ មកធ្វើពិធីហ្ជាច្ជនិងគោរពបូជាវិហារគ្រិស្តដែលខ្លួនបានឲ្យគេសាងសង់នៅឯយេមេននោះវិញ ។ អាប់រ៉ហ្វាស្ហ៊ុមានដំរីជារបៀបពលដែរដែលគេកម្រឃើញនៅដែនដីអារ៉ាប៊ី ។ ក្នុងប្រវត្តិសាស្ត្រគេហៅទ័ពដំរីនេះថា "អាស្ហ៊ហ្ជាប៊ុល-ហ្វីល (أصحاب الفيل)" ឬ "បនម្ចាស់ដំរី" ។

ពេលមកដល់បរិវេណម៉ាក់កាស្ហ៊ុ អាប់រ៉ហ្វាស្ហ៊ុបានចាប់អូដ្ឋរបស់អ៊ុប់ឌុល មុត្តត៊ុលិប ជីតារបស់ព្រះសាស្តាﷺ ។ ពេលអ៊ុប់ឌុល មុត្តត៊ុលិបទៅជួបអាប់រ៉ហ្វាស្ហ៊ុៗគិតថាអ៊ុប់ឌុល មុត្តត៊ុលិបនឹងសូមកុំឲ្យខ្លួនកម្ទេចកាក់ុបាស្ហ៊ុ ។ តែអ៊ុប់ឌុល មុត្តត៊ុលិបសូមអាប់រ៉ហ្វាស្ហ៊ុឲ្យប្រគល់តែអូដ្ឋមកលោកវិញ ។ អាប់រ៉ហ្វាស្ហ៊ុបានចំអកឲ្យអ៊ុប់ឌុល មុត្តត៊ុលិបថា៖ "ខ្ញុំមកក្នុងគោលបំណងកម្ទេចបូជនីយដ្ឋានរបស់អស់លោក តែលោកនិយាយតែអំពីរឿងអូដ្ឋលោក !" អ៊ុប់ឌុល មុត្តត៊ុលិបបានតបអាប់រ៉ហ្វាស្ហ៊ុវិញដោយចម្លើយដ៏ល្បីល្បាញនេះគឺ៖ "ខ្ញុំជាម្ចាស់អូដ្ឋ ខ្ញុំមករកអូដ្ឋខ្ញុំ ។ ឯកាក់ុបាស្ហ៊ុក៏មានព្រះម្ចាស់វាដែរ ដែលមើលថែរក្សាវា ។"

ព័ត៌មានលំអិតនេះ បញ្ជាក់ឲ្យដឹងថាបុព្វបុរសរបស់ព្រះសាស្តាﷺក៏ជាអ្នកស្និតស្នាញគោរពសក្ការៈអល់ឡោះហ្ស៊ﷻដែរ ។

អាប់រ៉ហ្វាស្ហ៊ុមិនបានយកចិត្តទុកដាក់នឹងពាក្យព្រមាននេះទេ គិតតែវាយយកកាក់ុបាស្ហ៊ុជាមួយទ័ពដំរី ។ ស៊ូរ៉ោះត៊ុ៍ថែងអំពីអ្វីដែលកើតឡើងចំពោះទ័ពរបស់អាប់រ៉ហ្វាស្ហ៊ុ ។

អាយ៉ាស្ហ៊ុ ១. ទ័ពព្រហើនត្រូវបង្ក្រាបដោយសត្វស្លាបតូចៗ ជញ្ជូនដុំថ្មដោយចំពុះនិងក្រញ៉ាំជើង ។ ដុំថ្មនីមួយៗត្រូវគោលដៅវា សម្លាប់មនុស្សនិងសត្វយ៉ាងទាន់ហាន់ ។ អល់ឡោះហ្ស៊ﷻបង្ហាញឲ្យឃើញថាទ័ពដ៏ខ្លាំងរបស់អាប់រ៉ហ្វាស្ហ៊ុត្រូវ

វិនាសដោយសារសត្វលោកតូចជាងគេរបស់ព្រះអង្គ عز وجل ។

អាយ៉ាស្ហ់ ២. អាយ៉ាស្ហ់នេះផ្តោតទៅលើការជ្រួលច្របល់ ដែលបានកើតឡើងនៅក្នុងទ័ពពេលឃើញហ្វូងសត្វស្លាបមកដល់ ។ ស្លាប់ច្រើននៅនឹងកន្លែង ចំណែកឯអ្នកនៅរស់ រាប់ទាំងអាប់រ៉ហ្វាស្ហ់ផង បានរត់យករស់ ។

អាយ៉ាស្ហ់ ៣, ៤. សត្វស្លាបតូចពិតតែវាមានលទ្ធភាពធំធេង ព្រោះពួកវាមានអល់ឡោះហ្វ៍ عز وجل ជួយ ។

អាយ៉ាស្ហ់ ៥. ទ័ពដែលនៅសេសសល់ ក្រោយពីសត្វស្លាបបានទៅអស់នោះប្រៀបបាននឹងស្មៅអៀងគោ ដាច់ខ្ទេចខ្ទី ឥតប្រយោជន៍ ។

អុីមុាំយ៉ា្ជក់ហ្វារ អាស្ហ-ស្វ៉ឌិក្ហ صلوات الله عليه والسلام បានសរសេរផ្ទាល់ដៃថា៖ "ពេលអស់លោកនៅពីមុខសត្រូវ ចូរសម្លឹងមើលមុខសត្រូវនោះ ហើយសូត្រស៊ូរ៉ោះត្ហ៍ អាល់-ហ្វីល ។"



# ការអនុវត្ត ៣

១) ចូរអ្នកទន្ទេញស៊ូរ៉ោះត៍ឲ្យត្រូវម៉ាខ៏រីច្ជនិងស្របតាមច្បាប់ស្វូត្រ ។
២) ចូរធ្វើលំហាត់ ១ ។

# លំហាត់ ១

ចូរសរសេរអ្វីៗដែលអ្នកបានសិក្សាពីសូរ៉ោះត៍ អាល់-ហ្វីល ។

សូរ៉ោះត៍ អាល់-ហ្វីល

## មេរៀនទី ៤

# ស៊ូរ៉ោះតុ៍ អាល់-ក្វូដរ៍ - ទន្ទេញចាំរត់មាត់ - តាហ្វសៀរ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

إِنَّا أَنْزَلْنَاهُ فِي لَيْلَةِ الْقَدْرِ ۚ

*ពិតណាស់ យើងបានដាក់វាចុះមក (គឺយើងបានបើកឲ្យដឹងនូវគួរអាន) នាពេលយប់ព្រះបុព្វបញ្ញត្តិ ។*

وَمَا أَدْرَاكَ مَا لَيْلَةُ الْقَدْرِ ط

*តើអ្នកដឹងបានដូចម្តេចថាអ្វីគឺយប់ព្រះបុព្វបញ្ញត្តិ ?*

لَيْلَةُ الْقَدْرِ ۙ خَيْرٌ مِنْ أَلْفِ شَهْرٍ ط

*យប់ព្រះបុព្វបញ្ញត្តិប្រសើរជាងមួយពាន់ខែ ។*

تَنَزَّلُ الْمَلَائِكَةُ وَالرُّوْحُ فِيْهَا بِإِذْنِ رَبِّهِمْ ۚ مِنْ كُلِّ أَمْرٍ ۙ

*បណ្តាទេវតានិងព្រះវិញ្ញាណនឹងចុះមកក្នុងយប់នេះ ដោយការអនុញ្ញាតរបស់ព្រះម្ចាស់ពួកគេមកលើគ្រប់រឿង ។*

سَلَامٌ ۛ هِيَ حَتّٰى مَطْلَعِ الْفَجْرِ ۚ

*[យប់នេះប្រកបដោយ]សិរីសួស្តីរហូតដល់សេតារុណ (ពេលមុនថ្ងៃរះ) ។*

អល់ឡោះហ៍ﷻបានដាក់ស៊ូរ៉ោះតុ៍នេះមកនៅឯម៉ាក់កាស់ មាន ៥ អាយ៉ាស់ ។ ន័យដើមរបស់ពាក្យ "អាល់-ក្វូដរ៍" គឺ "រុងរឿង" ឬ "ថ្កើងថ្កាន" ។ យោងទៅលើឫសគល់របស់ពាក្យនេះ ពាក្យនេះមានន័យថា "សម្រេចជាស្រេច" ឬ "កំណត់" ឬ "ដឹង

មុន" ។

# ការអនុវត្តិ ៤

១) ចូរអ្នកទន្ទេញឲ្យចាំស៊ូរ៉ោះត៍ឲ្យត្រូវម៉ាខ៏រីច្ចនិងស្របតាមច្បាប់សូត្រ ។
២) ចូរធ្វើលំហាត់ ៣ ។

**មេរៀនទី ៥**

# ស៊ូរ៉ោះត៍ អាល់-ក្វាដ្រ៍ - ទន្ទេញចាំរត់មាត់ - តាហ្វ់សៀរ

ក្នុងយប់ អាល់-ក្វាដ្រ៍ គេនឹងសម្រេចឲ្យម្នាក់បានអ្វីក្នុងឆ្នាំ ។ ដូច្នេះឯងបានជាព្រះសាស្តាﷺបានប្រាប់យើងឲ្យចំណាយពេលធ្វើការបួងសួង ពេញមួយយប់នេះឲ្យយើងអង្វរករសូមខមាទោសនិងបួងសួងសូមឲ្យបំណងយើងបានសម្រេច ។

អាយ៉ាស់ ១ - អល់ឡោះហ្វ៍عزّ وجلّបានដាក់ព្រះគម្ពីរមកឲ្យព្រះសាស្តាﷺជាចំពូកនៅក្នុងយប់នេះ ។ បន្ទាប់មកព្រះអង្គﷺប្រកាសប្រាប់មនុស្សដោយភាគៗតាមព្រះរាជបង្គាប់របស់អល់ឡោះហ្វ៍عزّ وجلّតាមរយៈយ៉ីបរ៉អ៊ីលعليه السلام ។

អាយ៉ាស់ ២ - នេះគឺសំណួរព្រលយសម្ដីថា មនុស្សមិនអាចយល់ មិនអាចវាស់ស្ទង់កុសលផលបុណ្យទាំងអស់ក្នុងយប់នេះបានទេ ។

អាយ៉ាស់ ៣ - "មួយពាន់ខែ" ត្រូវយល់ថារយៈពេលដ៏យូរ ។ បានសេចក្ដីថាការយល់ដឹងមួយភ្លែតដែលគេទទួលបានក្នុងយប់នេះ ក្រោមការដឹកនាំរបស់អល់ឡោះហ្វ៍عزّ وجلّ ប្រសើរលើសការចំណាយពេលមួយពាន់ខែនៅក្នុងការអវិជ្ជា ។

អាយ៉ាស់ ៤ - អាយ៉ាស់នេះរៀបរាប់អំពីបណ្ដាទេវតានិងយ៉ីបរ៉អ៊ីលعليه السلامដែលចុះមកលើផែនដីក្នុងអំឡុងយប់នេះជាបន្តបន្ទាប់មិនដាច់ មកជូនពររបស់អល់ឡោះហ្វ៍عزّ وجلّឲ្យទៅបណ្ដាអ្នកមានសទ្ធា ដែលមិនដេកក្នុងយប់នេះដើម្បីបួងសួងអល់ឡោះហ្វ៍عزّ وجلّ ។

អាយ៉ាស់ ៥ - អាយ៉ាស់នេះបញ្ជាក់ថាអល់ឡោះហ្វ៍عزّ وجلّប្រទានសិរីសួស្ដី ក្នុងនាមនៃព្រះមេត្តាករុណាពិសេសរបស់ព្រះអង្គعزّ وجلّ ពេញមួយយប់នេះគ្រប់ទីកន្លែងរហូតដល់ថ្ងៃថ្មី ។

ព្រះសាស្តា ﷺ មានព្រះវចនៈថាអ្នកណាសូត្រស៊ូរ៉ោះត្ចុ័នេះ អល់ឡោះហ្ ﷻ រាប់អ្នកនោះថាបានកាន់សីលត្រណមមួយខែរ៉ម៉ាឍន និងបានលះបង់ពេលវេលាក្នុងយប់អាល់-កទ្ទ័រដើម្បីគោរពបូជាព្រះអ្នកបង្កើតរបស់ខ្លួន ។

# លំហាត់ ៣

ចូរសរសេរអ្វីៗដែលអ្នកបានសិក្សាពីស្ទូរ៉ោះត្ទ៍ អាល់-ក្ទដ្ស៍ ។

ស្ទូរ៉ោះត្ទ៍ អាល់-ក្ទដ្ស៍

## មេរៀនទី ៦

# ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة)
# ហ៊្វូរុហ្វ អ៊ិស្ហារ (الإِظْهَار)

មានច្រើនរបៀបសូត្រហ្វ៊ូរុហ្វ នូន សាគីណាស់ (គឺនូនស្លាប់) ដោយផ្អែកទៅលើហ្វ៊ូរុហ្វដែលនូនស្លាប់នេះជួប (គឺហ្វ៊ូរុហ្វដែលនៅពីក្រោយនូនស្លាប់នេះ) ។

បើ نْ (នូនស្លាប់) ឬ ហ្វ៊ូរុហ្វមានតាន់វិន ជួបហ្វ៊ូរុហ្វទាំង ៦ តួនេះ ត្រូវសូត្រ នូន ឲ្យច្បាស់ ។

ا ح خ ع غ ه

# ការអនុវត្តិ ៦

១) ចូរអ្នកអានពាក្យខាងក្រោមនេះនិងព្យាយាមចងចាំន័យរបស់វា ។

غَنِيٌّ حَمِيْدٌ (ក៏នីយុន ហាមីឌុន) - ទ្រង់គ្រប់គ្រាន់សម្រាប់ព្រះអង្គឯង (មិនត្រូវការអ្នកណាទេ) ព្រះអង្គសមជាទីសើ្ញចសរសើរ ។ (ស៊.៣១ អា.១២)

عَذَابٌ أَلِيْمٌ (អ៊ាស្ហាប៊ុន អាលីមុន) - ទណ្ឌកម្មដ៏ឈឺចាប់ ។ (ស៊.២ អា.១០)

يَنْهٰى (យ៉ាន់ហ្វា) - ហាមឃាត់ ។ (ស៊.៩៦ អា.៩) ។

២) ចូរសូត្រគួរអាន ។

៣) ចូរធ្វើលំហាត់ ៤ ។

## លំហាត់ ៤

ច្បាប់អ៊ីស្ដហ្វារឲ្យស្ទាត់ នូន ឲ្យច្បាស់ ។

ចូរបំពេញរូបអក្សរនូនខាងក្រោមនេះ ដោយហ្វ៊ូរុហ្វទាំងអស់នៅក្នុងច្បាប់អ៊ីស្ដហ្វារ ។



**មេរៀនទី ៧**

# ច្បាប់សូត្រ នូន សាគីណាស្ទ់ (النون الساكنة)
# ហ៊្វូរុហ្វ អ៊ីក្ទ្បាប់ (ឬ ក្វល់ប៍ الإقلاب/ القلب)

الإقلاب/ القلب មានន័យថាប្តូរ ។

មានច្រើនរបៀបសូត្រហ៊្វូរុហ្វ នូន សាគីណាស្ទ់ (គឺនូនស្លាប់) ដោយផ្អែកទៅលើហ៊្វូរុហ្វដែលនូនស្លាប់នេះជួប (គឺហ៊្វូរុហ្វដែលនៅពីក្រោយនូនស្លាប់នេះ) ។

បើ نْ (នូនស្លាប់) ឬ ហ៊្វូរុហ្វមានតាន់វិន ជួប ب ។ ត្រូវសូត្រ នូន ដូច មីម ។

សម្លេងមីមងំនៅត្រង់ច្រមុះ ។

គេច្រើនតែសរសេរ م (កូនមីម) នៅពីលើ នៅចន្លោះ نْ (នូនស្លាប់) ឬ ហ៊្វូរុហ្វមានតាន់វិននិង ب តែបើពុំមានកូនមីមនេះទេក៏ត្រូវប្រើច្បាប់នេះដែរ ។

## ការអនុវត្តិ ៧

១) ចូរអ្នកអានពាក្យខាងក្រោមនេះនិងព្យាយាមចងចាំន័យរបស់វា ។

| | |
|---|---|
| وَيُؤْمِنْ بِاللَّهِ | (វ៉ាយុមីម ប៊ីលឡាស្ទ់) - ជឿអល់ឡោះហ្ន៍ ។ (ស៊.២ អា.២៥៦) |
| مَنْ بَعَثَنَا | (ម៉ាំបាអ៊ាស្នាណា) - អ្នកណាបានធ្វើឲ្យយើងរស់ឡើង ។ (ស៊.៣៦ អា.៥២) |
| مِنْ بَعْدِهِ | (មីមបាក់ឌីហ្វ៊ី) - អត់ពីគេ ។ (ស៊.២ អា.៥១) ។ |
| وَمَنْ بَلَغَ | (វ៉ា ម៉ាំបាឡាក៏) - បុគ្គលដែលគួរអានេះទៅដល់ ។ (ស៊.៦ អា.១៩) |

២) ចូរសូត្រគួរអាន ។
៣) ចូរធ្វើលំហាត់ ៥ ។

# លំហាត់ ៥

ច្បាប់អ៊ីក្ទូឡាប់ឲ្យសូត្រអក្សរនូនដូចអក្សរមីម ។
ចូរបំពេញរូបអក្សរមីមខាងក្រោមនេះដោយហ្វ៊ូរុហ្វនៅក្នុងច្បាប់អ៊ីក្ទូឡាប់ ។



**មេរៀនទី ៨**

# ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة)
# ហ៊្វូរុហ្វ អ៊ីដ្ហ្គុំ

មានច្រើនរបៀបសូត្រហ៊្វូរុហ្វ នូន សាគីណាស់ (គឺនូនស្លាប់) ដោយផ្អែកទៅលើហ៊្វូរុហ្វដែលនូនស្លាប់នេះជួប (គឺហ៊្វូរុហ្វដែលនៅពីក្រោយនូនស្លាប់នេះ) ។

អ៊ីដ្ហ្គុំមានន័យថាភ្ជាប់ហ៊្វូរុហ្វជាមួយហ៊្វូរុហ្វឯទៀត ។

ហ៊្វូរុហ្វអ៊ីដ្ហ្គុំមាន ៦ តួគឺៈ

ر ل م ن و ي

ដើម្បីចាំជាប់ក្នុងចិត្តចូរចងចាំពាក្យ يرملون (យ៉ារម៉ាលូន) ដែលមានគ្រប់តួអក្សរអ៊ីដ្ហ្គុំទាំង ៦ នេះ ។

បើ نْ (នូនស្លាប់) ឬ ហ៊្វូរុហ្វមានតាន់វិន ជួបតួអក្សរណាមួយក្នុងចំណោមតួអក្សរទាំង ៦ នេះ គេមិនសូត្រអក្សរនូនទេ គេសូត្រហ៊្វូរុហ្វបន្ទាប់នូននេះជាមួយតាស្ឌ់ឌីដ្ឌ (ពោលគឺ គេសូត្រហ៊្វូរុហ្វជួប نْ នេះឬហ៊្វូរុហ្វមានតាន់វិន ដោយដាក់ស្ហាដ្ឌ់ដាស់ពីលើវា) ។

អ៊ីដ្ហ្គុំជាមួយហ៊្វូរុហ្វ ل ر គេមិនសូត្រ នូន ទាល់តែសោះ (ពោលគឺបាត់សម្លេង នូន) ។

អ៊ីដ្ហ្គុំជាមួយហ៊្វូរុហ្វ ن م គេសូត្រហ៊្វូរុហ្វទាំងនេះដោយមានសម្លេងងំត្រង់ច្រមុះវែងបន្តិច លាយសម្លេង នូន ស្រាលៗ ។

អ៊ីដ្ហ្គុំជាមួយហ៊្វូរុហ្វ ي و គេសូត្រហ៊្វូរុហ្វទាំងនេះដោយមានសម្លេងងំត្រង់ច្រមុះវែងបន្តិច ដោយលាយសម្លេង នូន ស្រាលៗ ។

គេច្រើនតែសរសេរ តាស្ឌ់ឌីដ្ឌ (ឬ ស្ហាដ្ឌ់ដាស់) តែបើពុំមានតាស្ឌ់ឌីដ្ឌ (ឬ ស្ហាដ្ឌ់ដាស់) ទេក៏ត្រូវប្រើច្បាប់នេះដែរ ។

# ការអនុវត្តិ ៨

១) ចូរអ្នកអានពាក្យខាងក្រោមនេះនិងព្យាយាមចងចាំន័យរបស់វាផង ។

| | |
|---|---|
| أَن يَقُولَ | (អែយ៉ាគូឡា) - ព្រះអង្គប្រាប់វាថា ។ (ស៊ូរ៉ោះត៍ យ៉ាស៊ីន អាយ៉ាស់ ២ (៣៦:៨២)) |
| مُّحَمَّدٌ رَّسُولُ ٱللَّهِ | (មូហាំម៉ាឌូររ៉ស៊ូលុលឡោះហ៍) - មូហាំម៉ាដ់ជាព្រះសាសនៈទូត របស់អល់ឡោះហ៍ ។ (ស៊ូរ៉ោះត៍ អាល់-ហ្វាត់ហ៍ អាយ៉ាស់ ២៩ (៤៨:២៩)) |
| وَإِنْ نَّشَأْ | (វ៉ាអ៊ិនណាស្ញាអ៍) - បើយើងប្រាថ្នា ។ (ស៊ូរ៉ោះត៍ យ៉ាស៊ីន អាយ៉ាស់ ២ (៣៦:៤៣)) ។ |
| غَفُورًا رَّحِيْمًا | (ក៏ហ្វូររ៉ហ៊ីម) - ទ្រង់អត់ឱន ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។ (ស៊ូរ៉ោះត៍ អាន់-នីសាអ៍ អាយ៉ាស់ ២៣ (៤:២៣)) |
| إِمَامٍ مُّبِيْنٍ | (អ៊ីម៉ាមីមមូប៊ីន) - អ៊ីមុាំច្បាស់លាស់ ។ (ស៊ូរ៉ោះត៍ យ៉ាស៊ីន អាយ៉ាស់ ១២ (៣៦:១២)) |

២) ចូរសូត្រគូរអាន ។

៣) ចូរធ្វើលំហាត់ ៦ ។

# លំហាត់ ៦

ក្នុងច្បាប់អ៊ីដ្ហ្កំ ជាញឹកញយ គេមិនសូត្រ នូន ទេ ។ ចូរបំពេញរូបមាត់ដោយហ៊្វរុហ្វដែលពាក់ព័ន្ធនឹងច្បាប់នេះ ។ បន្ទាប់មក ចូរគូសខ្វែងដោយសញ្ញាខ្វែងធំពីលើរូបមាត់នេះ ព្រោះពេលនូនស្លាប់ ជួបហ៊្វរុហ្វទាំងនេះ គេមិនសូត្រអក្សរ នូន សោះ ។



ចូរបំពេញរូបមាត់ទីពីរដោយហ៊្វរុហ្វដែលពាក់ព័ន្ធនឹងច្បាប់អ៊ីដ្ហ្កំ ។ ហ៊្វរុហ្វដែលប្តូរសម្លេងដោយមានសម្លេងងំលាយសម្លេង នូន បន្តិច ។



ចូរបំពេញរូបច្រមុះដោយហ៊្វរុហ្វដែលពាក់ព័ន្ធនឹងច្បាប់អ៊ីដ្ហ្កំ ។ ហ៊្វរុហ្វដែលមានសម្លេងត្រង់ច្រមុះដោយលាយសម្លេង នូន ស្រាលៗ ។



**មេរៀនទី ៩**

# ច្បាប់សូត្រ នូន សាគីណាស់ (النون الساكنة)
# ហ៊្វូរុហ្វ អ៊ិះខ្ហ្វាអ៍ (الإِخْفَاء)

មានច្រើនរបៀបសូត្រហ៊្វូរុហ្វ នូន សាគីណាស់ (គឺនូនស្លាប់) ដោយផ្អែកទៅលើហ៊្វូរុហ្វដែលនូនស្លាប់នេះជួប (គឺហ៊្វូរុហ្វដែលនៅពីក្រោយនូនស្លាប់នេះ) ។

បើ نْ (នូនស្លាប់) ឬ ហ៊្វូរុហ្វមានតាន់វិន ជួបហ៊្វូរុហ្វ ១៥ តួនេះ គេសូត្រ នូន ងំត្រង់ច្រមុះ ដោយមានសម្លេងចន្លោះហ៊្វូរុហ្វអ៊ិដ្ហគុំនិងហ៊្វូរុហ្វអ៊ិស្ហហ្ការ ។ ពេលសូត្រ នូន គេមិនដាក់អណ្តាតផ្ទឹបនឹងពិតានមាត់ទេ គេទុកឲ្យមានចន្លោះបន្តិច ។ និយាយឲ្យស្រួលស្តាប់គឺសូត្រឲ្យមានសម្លេងរវាងអក្សរ "ន" និង "ង" ។

ت ث ج د ذ ز س ش ص ض ط ظ ف ق ك

# ការអនុវត្តិ ៩

១) ចូរអ្នកអានពាក្យខាងក្រោមនេះនិងព្យាយាមចងចាំន័យរបស់វាផង ។

فَانْصُرْنَا - ដូច្នេះសូមព្រះអង្គមេត្តាជួយអស់ទូលព្រះបង្គំជាខ្ញុំ ។ (ស៊ូរ៉ោះត៊ អាល់-បាក៊ារ៉ោះត៊ អាយ៉ាស់ ២៨៦ (២:២៨៦))

كُنْتُمْ - ពួកអ្នក ។ (ស៊ូរ៉ោះត៊ អាល់-បាក៊ារ៉ោះត៊ អាយ៉ាស់ ២៣ (២:២៣))

عِنْدَ - ចំពោះ ។ (ស៊ូរ៉ោះត៊ អាល់-បាក៊ារ៉ោះត៊ អាយ៉ាស់ ៥៤ (២:៥៤)) ។

تَنْزِيْلَ - ត្រូវប្រទានចុះមក ។ (ស៊ូរ៉ោះត៊ យ៉ាស៊ីន អាយ៉ាស់ ៥ (៣៦:៥))

شَيْءٍ قَدِيْرٌ - មានសព្វានុភាពលើសព្វសារពើ ។ (ស៊ូរ៉ោះត៊ អាល់-បាក៊ារ៉ោះត៊

អាយ៉ាស់ ២០ (២:២០))

២) ចូរសូត្រគួរអាន ។
៣) ចូរធ្វើលំហាត់ ៧ ។

**លំហាត់ ៧**

ពេលនូនស្លាប់ជួបហ៊្វរុហ្វអ៊ិះខ៌ហ្វាអ៌ គេសូត្រនូនងំត្រង់ច្រមុះ ដោយមានសម្លេងចន្លោះហ៊្វរុហ្វអ៊ីដ្ហកុំនិងហ៊្វរុហ្វអ៊ីស្ហហ្វារ ។

ចូរសរសេរនៅលើរូបច្រមុះខាងក្រោមនេះ ហ៊្វរុហ្វទាំងអស់ពាក់ព័ន្ធនឹងច្បាប់នេះ ។

**អ៊ីដ្ហកុំ**



**អ៊ីស្ហហ្វារ**

**មេរៀនទី ១០**

# ស៊ូរ៉ោះតុ៏ អាល់-ឡាហាប់ - ទន្ទេញចាំរត់មាត់ - តាហ្ញ់សៀរ

بِسۡمِ اللّٰهِ الرَّحۡمٰنِ الرَّحِيۡمِ

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

تَبَّتْ يَدَا أَبِي لَهَبٍ وَتَبَّ ۗ

*សូមឲ្យដៃទាំងពីររបស់អាប៊ូ-ឡាហាប់វិនាស សូមឲ្យ[ខ្លួន]គេវិនាស[ដែរ] ។*

مَا أَغْنٰى عَنْهُ مَالُهُ وَمَا كَسَبَ ۗ

*ទ្រព្យសម្បត្តិរបស់គេនិងអ្វីដែលគេរកបានពុំមានប្រយោជន៍សម្រាប់គេទេ ។*

سَيَصْلٰى نَارًا ذَاتَ لَهَبٍ ۚ صلى

*គេនឹងចូលក្នុងភ្លើងដែលឆេះសន្ធោសន្ធៅ*

وَامْرَأَتُهُ ۗ حَمَّالَةَ الْحَطَبِ ۚ

*និងភរិយាគេ អ្នកទូលឧស*

فِيْ جِيْدِهَا حَبْلٌ مِنْ مَسَدٍ ٤

*លើកនាងមានខ្សែព្រួរធ្វើអំពីសរសៃតាលព្រឹក្ស ។*

អល់ឡោះហ៍ﷻបានដាក់ស៊ូរ៉ោះតុ៏នេះមកនៅឯម៉ាក់កាស់ មាន ៥ អាយ៉ាស់ ។

១) ចូរអ្នកទន្ទេញស៊ូរ៉ោះតុ៏ឲ្យត្រូវម៉ាខ៏រីចូនិងស្របតាមច្បាប់សូត្រ ។
២) ចូរធ្វើលំហាត់ ៨ ។

## មេរៀនទី ១១

# ស៊ូរ៉ោះត៍ អាល់-ឡាហាប់ - ទន្ទេញចាំរត់មាត់ - តាហ្វសៀរ

ឈ្មោះរបស់ស៊ូរ៉ោះត៍នេះផ្តោតទៅលើ អាប៊ូ ឡាហាប់ ដែលជាបងប្អូនជីដូនមួយរបស់ អាប់ឌុលម៉ុត្តលិប និងជាឪពុកមារបស់ព្រះសាស្តាﷺយើង ។

អាប៊ូ ឡាហាប់ជាសត្រូវធំមួយរបស់ព្រះសាស្តាﷺនិងអ៊ីស្លាម ។ ឈ្មោះពិតរបស់គាត់គឺ អាប់ឌុល-អ៊ុស្សា (عبد العزّى) តែព្រោះតែគាត់មានចារិតឆេវឆាវបានជាគេហៅគាត់ថា អាប៊ូ ឡាហាប់ (មានន័យសាមញ្ញថាឪភ្លើង) ។

ស៊ូរ៉ោះត៍នេះបញ្ជាក់ប្រាប់យើងថា ទ្រព្យសម្បត្តិនិងអំណាចដែលបុគ្គលមាននៅក្នុងលោកនេះពុំមានប្រយោជន៍ទេក្នុងថ្ងៃជំនុំជម្រះ បើបុគ្គលនោះបានសាងទង្វើអាក្រក់ ។

អាយ៉ាស់ ១. អាយ៉ាស់នេះចែងអំពីដៃរបស់ អាប៊ូ ឡាហាប់ ព្រោះគាត់បានគ្រវែងព្រះសាស្តាﷺដោយដុំថ្មកាលគេហៅគាត់ឲ្យមករកសាសនាអ៊ីស្លាម នាស៊ុល អាស្ស៊ីរ៉ោះត៍ (ذو العشيرة) ។

អាយ៉ាស់ ២. ពេលគេបានព្រមានគាត់អំពីភ្លើងនរក គាត់បានអួតថាទ្រព្យសម្បត្តិគាត់នឹងជួយឲ្យគាត់រួចផុតពីអន្តរាយ ។

អាយ៉ាស់ ៣. ត្រង់នេះគេបានប្រាប់គាត់ថា គាត់នឹងត្រូវធ្វើទណ្ឌកម្មដោយភ្លើងនរកដែលបានប្រព្រឹត្តទង្វើអាក្រក់ ។

អាយ៉ាស់ ៤. អ៊ុម យ៉ាមីឡាស់ ជាភរិយារបស់ អាប៊ូ ឡាហាប់ ពេលយប់គាត់ធ្លាប់តែយកមែកឈើមានបន្លាទៅដាក់លើផ្លូវដែលព្រះសាស្តាﷺដើរ ក្នុងគោលបំណងធ្វើឲ្យជើងព្រះអង្គﷺរបួស ។ អាយ៉ាស់នេះសន្យាថាគាត់នឹងត្រូវទទួលទណ្ឌកម្មដូចស្វាមីគាត់ដែរ ។

អាយ៉ាស់ ៥. ថ្ងៃមួយ អ៊ុម យ៉ាមីឡាស់ មានគ្រោះថ្នាក់ ត្រូវខ្សែដែលគាត់ប្រើសម្រាប់ចងឈើបន្លានោះរឹតកគាត់ ។ ថ្ងៃជំនុំជម្រះ គាត់នឹងត្រូវខ្សែឆេះភ្លើងរឹកព្រោះគាត់ជានារីកំណាច ។

# លំហាត់ ៨

ចូរសរសេរអ្វីៗដែលអ្នកបានសិក្សាពីស៊ូរ៉ោះត្ទ៍ អាល់-ឡាហ្ហាប់ ។

ស៊ូរ៉ោះត្ទ៍ អាល់-ឡាហ្ហាប់

## មេរៀនទី ១២

# ស៊ូរ៉ោះត៍ អាន់-ណាស្វ៍រ - ទន្ទេញចាំរត់មាត់ - តាហ្វ៍សៀរ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

*ដោយនូវព្រះនាមអល់ឡោះហ្វ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

إِذَا جَاءَ نَصْرُ اللّٰهِ وَالْفَتْحُ ۙ

*កាលណាជំនួយរបស់អល់ឡោះហ្វ៍មកដល់និងជ័យជំនះ*

وَرَأَيْتَ النَّاسَ يَدْخُلُوْنَ فِيْ دِيْنِ اللّٰهِ أَفْوَاجًا ۙ

*អ្នកឃើញមនុស្សចូលមកកាន់ព្រះសាសនាអល់ឡោះហ្វ៍យ៉ាងពពាក់ពពូន*

فَسَبِّحْ بِحَمْدِ رَبِّكَ وَاسْتَغْفِرْهُ ؕ

*កាលនោះចូរអ្នកថ្វាយសេចក្ដីគោរពបូជាព្រះម្ចាស់អ្នក អង្វរបួងសួងសូមខមាទោសព្រះអង្គ ។*

إِنَّهُ كَانَ تَوَّابًا ۧ

*ពិតណាស់ ព្រះអង្គគឺព្រះដែលទទួលនូវការស្ដាយកំហុសខ្លួននិងការរាងចាល ។*

អល់ឡោះហ្វ៍ﷻបានដាក់ស៊ូរ៉ោះត៍នេះមកនៅឯម៉ាក់កាស្ទ៍ មាន ៣ អាយ៉ាស្ទ៍ ។

អាន់-ណាស្វ៍រ មានន័យថាជំនួយ សំដៅទៅលើជំនួយរបស់អល់ឡោះហ្វ៍ﷻ ដែលធ្វើឲ្យទង្វើទាំងអស់ប្រកបដោយជោគជ័យ ។

# ការអនុវត្ត ១២-១៣

១) ចូរអ្នកទន្ទេញស៊ូរ៉ោះត្ញ៉ឲ្យត្រូវម៉ាខ្រ៉ជ្ជ័និងស្របតាមច្បាប់ស៊ូត្រ ។

២) ចូរធ្វើលំហាត់ ១០ ។

**មេរៀនទី ១៣**

# ស៊ូរ៉ោះត៍ អាន់-ណាស្វ៍ - ទន្ទេញចាំរត់មាត់ - តាហ្វ៉សៀរ

អល់ឡោះហ្ជ៍ﷻបានដាក់ស៊ូរ៉ោះត៍នេះមក បន្ទាប់ពីពួកមុស្លីមបានវាយយកបានម៉ាក់កាស្ហ៍ដោយគ្មានមនុស្សស្លាប់និងដោយមិនបានបង្ហូរឈាម ។

ស៊ូរ៉ោះត៍នេះជាស៊ូរ៉ោះត៍មួយដែលត្រូវដាក់មកក្រោយគេ ។ ពួកមុស្លីមដឹងថាបេសកកម្មរបស់ព្រះសាស្ដាﷺជិតដល់ទីបញ្ចប់ ។

អាយ៉ាស្ហ៍ ១. អល់ឡោះហ្ជ៍ﷻបញ្ជាក់ថា ជ័យជំនះនិងសេចក្ដីសម្រេចដែលពួកមុស្លីមទទួលបានក្នុងការវាយយកម៉ាក់កាស្ហ៍នោះ មកពីព្រះអង្គﷻមួយគត់ ។ ដូចគ្នាដែរ យើងបានសម្រេចដោយសារតែជំនួយរបស់អល់ឡោះហ្ជ៍ﷻ យើងត្រូវសូមជំនួយព្រះអង្គﷻក្នុងកិច្ចការទាំងអស់ ។

អាយ៉ាស្ហ៍ ២. ក្រោយពីវាយយកម៉ាក់កាស្ហ៍បាន ពួកសត្រូវរបស់អ៊ីស្លាមបានដឹងថាពួកមុស្លីមមានអំណាចខ្លាំងឡើងមិនអាចបង្ក្រាបបានទេ ។ អាស្រ័យហេតុនេះ ប្រជាជាតិទាំងក្រុមៗ បន្តបន្ទាប់គ្នា មកជួបព្រះសាស្ដាﷺនៅឯម៉ាក់កាស្ហ៍ បន្ទាប់មកនៅឯម៉ាឌីនាស្ហ៍ ដើម្បីចូលសាសនាអ៊ីស្លាម ។

អាយ៉ាស្ហ៍ ៣. ពេលយើងមានជោគជ័យ យើងត្រូវបួងសួង លើកតម្កើងអល់ឡោះហ្ជ៍ﷻ ដើម្បីនឹងឲ្យជោគជ័យនោះមកដល់យើងដោយសារព្រះជំនួយនិងព្រះមេត្តារបស់ព្រះអង្គﷻ ។

"អ៊ីសតាក់ហ្វៀរ (اِسْتَغْفِرْ)" នៅក្នុងអាយ៉ាស្ហ៍នេះមានន័យថាសូមខមាទោសចំពោះព្រះសាស្ដាﷺ ព្រោះព្រះអង្គﷺអរិរុទ្ធ ។ "អ៊ីសតាក់ហ្វៀរ" មានន័យថាសូមជំនួយការពារពីកំហុសក្នុងនាមជាមុស្លីម និងការពារពីបំណងអាក្រក់របស់ពួកសត្រូវរបស់សាសនាអ៊ីស្លាម ។

អ៊ីម៉ាំយ៉ាក់កុំហ្វារ អាស្ហ៍-ស្វ៍ឌិក្ហ៍عليه والسلام صلوات اللهមានវចនៈថាអ្នកណាសូត្រស៊ូរ៉ោះត៍នេះក្នុងស្វ៍ឡាត៍វ៉ាយ៉ិបឬស្វ៍ឡាត៍មិនវ៉ាយ៉ិប អ្នកនោះនឹងឈ្នះសត្រូវដោយសារជំនួយរបស់អល់ឡោះហ្ជ៍ﷻ ។

គេឲ្យយើងសូត្រស៊ូរ៉ោះត៍នេះដែរពេលយើងបាត់របស់ ដើម្បីសូមជំនួយ

អល់ឡោះហ៊្ عزوجل ឲ្យរកឃើញវិញ ។

# លំហាត់ ១០

ចូរសរសេរអ្វីៗដែលអ្នកបានសិក្សាពីស៊ូរ៉ោះត្ត៍ អាន់-ណាស្ស់រ៍ ។

ស៊ូរ៉ោះត្ត៍ អាន់-ណាស្ស់រ៍

**មេរៀនទី ១៤**

# ស៊ូរ៉ោះត៍ អាល់-កៅស្ហារ - ទន្នេញចាំរត់មាត់ - តាហ្ស៊ៀរ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

*ដោយនូវព្រះនាមអល់ឡោះហ្ម៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

إِنَّا أَعْطَيْنَاكَ الْكَوْثَرَ ۝

*ពិតណាស់ យើងបានប្រទានអាល់-កៅស្ហារឲ្យអ្នក[មូហាំម៉ាដ៍អឺយ] ។*

فَصَلِّ لِرَبِّكَ وَانْحَرْ ۝

*ដូច្នេះ ចូរអ្នកធ្វើនមស្ការបូជាព្រះម្ចាស់អ្នកនិងធ្វើពលិកម្ម ។*

إِنَّ شَانِئَكَ هُوَ الْأَبْتَرُ ۝

*ពិតណាស់ សត្រូវរបស់អ្នកជាមនុស្សដាច់ពូជ ។*

អល់ឡោះហ្ម៍ عزّ وجلّ បានដាក់ស៊ូរ៉ោះត៍នេះមកនៅឯម៉ាក់កាស្ម៍ មាន ៣ អាយ៉ាស្ម៍ ។

ស៊ូរ៉ោះត៍គួរអាននេះខ្លីជាងគេ ។ កាលពួកមុស្លីមបានសួរព្រះសាស្តា ﷺ ថា ពាក្យ "កៅស្ហារ" មានន័យថាអ្វី ព្រះអង្គ ﷺ មានវចនៈថាជាឈ្មោះរបស់ប្រភពទឹកល្អបំផុតក្នុងឋានសួគ៌ ។ បណ្តាអ្នកមានសទ្ធាជ្រះថ្លានឹងបានផឹកទឹកនេះ ។ បន្ទាប់មកព្រះសាស្តា ﷺ បានបែរទៅរកអ៊ីមុាំអាលី صلوات الله عليه والسلام មានព្រះវចនៈថា៖ "អ្នក صلوات الله عليه والسلام ជាអ្នកចែកទឹកកៅស្ហារ ។"

អាយ៉ាស្ម៍ ១. កៅស្ហារមានន័យដែរថាភាពសម្បូរច្រើនលើសលន់ ផ្តោតទៅលើអ្វីៗដ៏ច្រើនដែលគេប្រទានឲ្យទៅព្រះសាស្តា ﷺ ក្នុងលោកនេះ និងក្នុងលោក

មុខ ។

អាយ៉ាស់ ២. ទោះបីអាយ៉ាស់នេះសម្រាប់ព្រះសាស្ដាﷺក៏ដោយ តែមានសេចក្ដីសំដៅទៅលើបណ្ដាអ្នក ដែលអល់ឡោះហ៍عزوجلប្រទានឲ្យនូវភាពសម្បូរលើសលន់ ។ អ្នកណាចង់បាននៅក្បែរអល់ឡោះហ៍عزوجل ចូរអ្នកនោះធ្វើពលីកម្មនិងស្ឡ៉ាត់ ។ ត្រង់នេះពលីកម្មមានន័យថាលះបង់ពេលវេលា ថវិកានិងជីវិតដែរនៅលើមាគ៌ាអល់ឡោះហ៍عزوجل ។

អាយ៉ាស់ ៣. កូនប្រុសទាំងអស់របស់ព្រះសាស្ដាﷺបានស្លាប់ តាំងពីនៅក្មេង ។ ពួកគូរ៉យ៉ស្ហ៍ខ្លះបានចំអកឲ្យព្រះអង្គﷺដោយហៅព្រះអង្គﷺថា "អាប់តារ" ពាក្យសម្រាប់ហៅសត្វដែលដាច់កន្ទុយ ។ ពួកគេនិយាយបញ្ឆិតបញ្ឆៀងថាព្រះសាស្ដាﷺពុំមានកូនចៅទេ ។ នៅក្នុងអាយ៉ាស់នេះ អល់ឡោះហ៍عزوجلបានសន្យាថា ពួកសត្រូវរបស់ព្រះអង្គﷺនោះទេ ពុំមែនព្រះអង្គﷺទេ ដែលនឹងទៅជា "អាប់តារ" នោះ ។

សព្វថ្ងៃនេះយើងឃើញពាក្យសន្យានេះទៅជាពិត ។ សព្វថ្ងៃនេះព្រះសាស្ដាﷺមានកូនចៅរាប់ពាន់នាក់ដែលយើងហៅថាសៃយិដ្ ។ ផ្ទុយទៅវិញ គេមិនឃើញមានកូនចៅរបស់ពួកសត្រូវមុនៗរបស់អ៊ីស្លាមទេ ។

អ៊ីមុាំយ៉ាក់ហ្វារ អាស្ហ៍-ស្ហ៍ឌិក្ហصلوات الله عليه والسلامមានវចនៈថាអ្នកណាសូត្រស៊ូរ៉ោះត៍នេះនៅក្នុងស្ឡ៉ាត់ គេនឹងអនុញ្ញាតឲ្យអ្នកនោះផឹកទឹកអណ្ដូងកៅស្ហ៍រ អ្នកនោះនឹងបានជួប បាននិយាយជាមួយព្រះសាស្ដាﷺ ។

# ការអនុវត្ត ១៤

១) ចូរអ្នកទន្ទេញស៊ូរ៉ោះត៍ឲ្យត្រូវម៉ាខ៍រីជ្និងស្របតាមច្បាប់សូត្រ ។
២) ចូរធ្វើលំហាត់ ១៣ ។

# លំហាត់ ១៣

ចូរសរសេរអ្វីៗដែលអ្នកបានសិក្សាពីស៊ូរ៉ោះត្ត៏ អាល់-កៅស្សារ ។

ស៊ូរ៉ោះត្ត៏ អាល់-កៅស្សារ

**មេរៀនទី ១៥**

# ស៊ូរ៉ោះតុ៍ អាល់-អាស្ស៍រ - ទន្ទេញចាំរត់មាត់ - តាហ្វ៍សៀរ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

*ដោយនូវព្រះនាមអល់ឡោះហ្វ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

وَالْعَصْرِ ۙ

*[អញសូមស្បថ]នឹងសម័យកាល ។*

إِنَّ الْإِنْسَانَ لَفِي خُسْرٍ ۙ

*ពិតណាស់ មនុស្សនៅក្នុងសេចក្តីវិនាស*

إِلَّا الَّذِينَ آمَنُوا وَعَمِلُوا الصَّالِحَاتِ وَتَوَاصَوْا بِالْحَقِّ وَتَوَاصَوْا بِالصَّبْرِ ۧ

*លើកលែងតែបណ្តាអ្នកដែលមានសទ្ធា សាងអំពើល្អ ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យទៅកាន់ការពិត ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យអត់ធ្មត់[នៅលើមាគ៌ាអល់ឡោះហ្វ៍] ។*

អល់ឡោះហ្វ៍ﷻបានដាក់ស៊ូរ៉ោះតុ៍នេះមកនៅឯម៉ាក់កាស់ មាន ៣ អាយ៉ាស់ ។

ឈ្មោះស៊ូរ៉ោះតុ៍នេះមកពីសាច់រឿងក្នុងអាយ៉ាស់ដំបូង ។ ស៊ូរ៉ោះតុ៍នេះថែងអំពីការប្រកាសប្រាប់គ្នាឲ្យចេះដឹងការពិតនិងឲ្យចេះអត់ធ្មត់ ។

## ការអនុវត្តិ ១៥-១៦

១) ចូរអ្នកទន្ទេញស៊ូរ៉ោះតុ៍ឲ្យត្រូវម៉ាខ៍រីចូនិងស្របតាមច្បាប់សូត្រ ។

២) ចូរធ្វើលំហាត់ ១៤ ។

# មេរៀនទី ១៦

## ស៊ូរ៉ោះត៍ អាល់-អាស្វ័រ - ទន្ទេញចាំរត់មាត់ - តាហ្វ៍សៀរ

អាយ៉ាស់ ១. "អាស្វ័រ" មានន័យថាសម័យកាល ផ្តោតទៅលើការផ្លាស់ប្តូរវេលាកាលជានិច្ចឥតឈប់ ។ លោកអ្នកប្រាជ្ញខ្លះថា "អាស្វ័រ" ស្តីអំពីពេលដែលអ៊ីម៉ាំម៉ាស់ឌីﷺនឹងដើបឡើង ។ ត្រង់នេះអល់ឡោះហ្វ៍ﷻស្បថនឹងពេលវេលា ។

អាយ៉ាស់ ២. ដែលថាមនុស្សនៅក្នុងសេចក្តីវិនាសនោះ បានសេចក្តីថាមនុស្សរហ័សវង្វេងណាស់ដោយសារស្រឡាញ់លោកនេះពេក ។ បើមិនប្រយ័តខ្លួនទេមនុស្សនឹងវង្វេងក្នុងការស្វែងរកការសប្បាយ ភ្លេចអល់ឡោះហ្វ៍ﷻ ។ អាយ៉ាស់បន្ទាប់បង្ហាញនូវគុណសម្បត្តិរបស់បណ្តាអ្នក ដែលខ្ជាប់ខ្ជួនមិនប្រែប្រួលនៅលើមាគ៌ាអល់ឡោះហ្វ៍ﷻ ។

គេបានសួរព្រះសាស្តាﷺអំពី "សេចក្តីវិនាស" ព្រះអង្គﷺមានព្រះវចនៈថា៖ "អ្នកណាមិនជឿអាស្វ់លុល-បៃត៍ (ព្រះរាជកុលដ្ឋានعليهم السلام) របស់ខ្ញុំﷺទេ អ្នកនោះនៅក្នុងសេចក្តីវិនាស ។"

អាយ៉ាស់ ៣. យើងឃើញនៅក្នុងអាយ៉ាស់នេះថាទង្វើប្រសើរគឺ៖

1. ជឿជាក់លើអល់ឡោះហ្វ៍ﷻ ។ ពោលគឺ ជឿនិងអនុវត្តិតាមអ្វីៗដែលព្រះអង្គបញ្ជាឲ្យធ្វើ ។

2. ធ្វើអំពើល្អដើម្បីផ្គាប់ចិត្តអល់ឡោះហ្វ៍ﷻ ។

3. ញុំាងមនុស្សឲ្យទៅរកផ្លូវល្អ ។ ព្យាយាមផ្សាយទ្រឹស្តីសាសនាអ៊ីស្លាមដោយសម្តីនិងដោយទង្វើ ។

4. មានការអត់ធ្មត់ ។ ទោះបីយើងមិនបានអ្វីដែលយើងចង់ទេនោះក៏ដោយ យើងត្រូវទុកចិត្តលើអល់ឡោះហ្វ៍ﷻនិងត្រូវអត់ធ្មត់ ។ អល់ឡោះហ្វ៍ﷻដឹងថាអ្វីដែលល្អសម្រាប់យើង ។

ព្រះសាស្តាﷺមានព្រះវចនៈថាអ្នកណាសូត្រស៊ូរ៉ោះត៍នេះ អ្នកនោះនឹងបាននៅក្នុងក្រុមបណ្តាអ្នកល្អក្នុងថ្ងៃជំនុំជម្រះ ។

# លំហាត់ ១៤

ចូរសរសេរអ្វីៗដែលអ្នកបានសិក្សាពីស៊ូរ៉ោះត្ត៍ អាល់-អុស្ស៊ូរ៍ ។

ស៊ូរ៉ោះត្ត៍ អាល់-អុស្ស៊ូរ៍

*Sources:*
imamia.org
shia974.fr
madressa.net
page-borders.com
openclipart.org